ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...០៥...សរណន

# សារាចរណែនាំ

## ស្តីពី

## ចំរាចធ្វើអាជីវកម្មជីករុករក និង បំផ្លាញវត្ថុបុរាណ

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ជាឃ្លាំងសម្បត្តិវប្បធម៌ ដែលសម្បូរបែបទៅដោយបុរាណវត្ថុនៅរាយប៉ាយទូទាំងប្រទេស រួមទាំងមហាប្រាសាទទាំងឡាយនៅលើដី និងវត្ថុបុរាណដែលកប់ក្នុងដី អស់កាលរាប់រយរាប់ពាន់ឆ្នាំ ដែលហៅថាកំណប់បុរាណវត្ថុរបស់បុព្វបុរសគ្រប់ជំនាន់ ។

សង្គ្រាមយូរអង្វែងទើបត្រូវបានបញ្ចប់ជាស្ថាពរបានធ្វើឱ្យវត្ថុបុរាណទាំងនោះខូចខាត បាត់បង់ និងមួយចំនួនធំត្រូវបានជនខិលខូចរួមគំនិតនឹងឈ្មួញបរទេសគាស់កកាយបំផ្លាញ លួចបញ្ជូនយកទៅលក់នៅទីផ្សារបរទេស ។ បច្ច័យទាំងនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការថែរក្សា និងជីករុករកវត្ថុបុរាណ សំរាប់ការយល់ដឹង និងចងក្រងជាឯកសារសិក្សាស្រាវជ្រាវទៅអនាគត ។

ក្នុងបំណងរក្សាស្នាដៃជាប្រវត្តិសាស្ត្រមានជាអាទិ៍ ប្រាង្គប្រាសាទ និងវត្ថុបុរាណទាំងអស់ ដែលជាសម្បត្តិវប្បធម៌ជាតិទុកសំរាប់ការយល់ដឹងដល់អនុជនជំនាន់ក្រោយ រាជរដ្ឋាភិបាលយកចិត្តទុកដាក់ អភិរក្សរាល់មរតកប្រវត្តិសាស្ត្រទាំងអស់ ដែលនៅសេសសល់ក្រោយការបំផ្លាញដោយធម្មជាតិ សង្គ្រាម និងអាជីវកម្មខុសច្បាប់ ដោយពួកឈ្មួញទុច្ចរិត ដើម្បីភាពគង់វង្សនៃសម្បត្តិវប្បធម៌មនុស្សលោក,

### រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម ÷

១_ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ អាជ្ញាធរអប្សរា សហការជាមួយអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុងទាំងអស់ រួមជាមួយបន្ទីរជំនាញពាក់ព័ន្ធ នៅក្នុងមូលដ្ឋាននីមួយៗធ្វើការកំណត់ទីតាំងដែលសង្ស័យថាមានកំណប់វត្ថុបុរាណប្រវត្តិសាស្ត្រ រួចចាត់វិធានការថែរក្សាការពារ ដោយចុះក្នុងបញ្ជីសារពើភ័ណ្ឌរដ្ឋ និងបោះបង្គោលដែន ត្រូវការពារឱ្យបានត្រឹមត្រូវ ។

២_ហាមឃាត់នៅទូទាំងប្រទេស រាល់ការជីកកកាយនៅក្នុងដី ដើម្បីរាវរកវត្ថុបុរាណ ការសាងសង់ លើទីតាំងដែលមានសំណល់បុរាណវត្ថុ ឬជាអតីតសំណង់ប្រវត្តិសាស្ត្រ មានជាអាទិ៍ទីតាំង ប្រាសាទបាក់បែក ជំរុំស្នាក់នៅ

របស់មនុស្សសម័យដើម "រូងភ្នំ", ទីកន្លែងសាសនា "វត្ត ចេតិយ ដំបូកអ្នកតា ឬដើមពោធិ៍" ។ល។ លើកលែងតែការជីករុករកផ្នែកបុរាណវិទ្យា ដែលមានលក្ខណៈប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ ក្នុងបំណងសិក្សាស្រាវជ្រាវ ហើយមានការអនុញ្ញាត្តិស្របច្បាប់ពីរាជរដ្ឋាភិបាលជាមុនសិន ។

៣_ ចំពោះមុខអាជ្ញាធរខេត្តគ្រប់ជាន់ថ្នាក់ ត្រូវសហការជាមួយនគរបាលបេតិកភ័ណ្ឌ មន្ទីរវប្បធម៌ខេត្ត និងកងកម្លាំងប្រដាប់អាវុធឈរជើងនៅនឹងកន្លែង ត្រូវចាត់វិធានការទប់ស្កាត់ជាបន្ទាន់ ចំពោះករណីគាស់បំផ្លាញ និងរុករកបុរាណវត្ថុដោយប្រជាជន និងឈ្មួញទុច្ចរិតមួយចំនួនតាមតំបន់ដូចខាងក្រោម ៖

- តំបន់បុរេប្រវត្តិសាស្ត្រភូមិស្នាយ និងភូមិថ្មី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
- តំបន់បុរេប្រវត្តិសាស្ត្រសម័យហ្វូណន នៅភ្នំដា ស្រុកអង្គរបុរី ខេត្តតាកែវ
- តំបន់បុរេប្រវត្តិសាស្ត្រមនុស្សសម័យដើមរស់នៅតាមគ្រប់ល្អាងភ្នំក្នុងខេត្តកំពត
- តំបន់ប្រាសាទសំបូរព្រៃគុក ស្រុកសំបូរ ខេត្តកំពង់ធំ
- តំបន់ប្រាសាទព្រះខ័នកំពង់ស្វាយ ខេត្តព្រះវិហារ
- តំបន់ភូមិមូល នៅចំការកៅស៊ូក្រែក-មេមត់ ក្នុងខេត្តកំពង់ចាម
- តំបន់រូងជានាង នៅចំណុចកំពស់ ៧១១ម៉ែត្រ ចំណុច **X0359707 & Y1290252** ភ្នំខ្នងស្រស់ ភូមិទំពាំងឃ្លៃ ឃុំប្រឡាយថ្មបាំង ខេត្តកោះកុង
- ចំនុចល្អាងស្លាន ភ្នំទាក់ទ្រាំង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

អាជ្ញាធរខេត្តពាក់ព័ន្ធក្នុងប្រការនេះត្រូវផ្តល់របាយការណ៍អំពីវិធានការ និងលទ្ធផលការងាររបស់ខ្លួនតាមរយៈខ្សែទទឹង និងខ្សែបណ្តោយមករាជរដ្ឋាភិបាលឱ្យបានជាប្រចាំ ។

៤_ រាជរដ្ឋាភិបាលសូមធ្វើការអំពាវនាវដល់ជនរួមជាតិទាំងអស់ដែលបាន និងកំពុងប្រកបរបរទទួលទាន ជីកកកាយវត្ថុបុរាណដោយភ្លេចខ្លួន និងមិនស្របច្បាប់ មេត្តាបញ្ឈប់ជាបន្ទាន់នូវសកម្មភាព ដែលជាទង្វើខុសឆ្គងទាំងនោះ ព្រោះអាចនាំទៅភាពផុតរលត់នៃមរតកវប្បធម៌ជាតិ។

៥_ ឈរលើស្មារតីភ្ញាក់រលឹកទាន់ពេលវេលា ជនរួមជាតិទាំងឡាយណាដែលបាន និងកំពុងកាន់កាប់ រាល់វត្ថុបុរាណទាំងអស់ មេត្តាបង្វែរប្រគល់ជូនរាជរដ្ឋាភិបាលវិញតាមរយៈអាជ្ញាធរដែនដី នៅនឹងកន្លែង ឬតាមសារមន្ទីរដែលនៅជិតខ្លួន ដើម្បីបញ្ជូនមករក្សាទុកឱ្យបានគង់វង្ស ។ មន្ត្រីអាជ្ញាធរដែលទទួលវត្ថុបុរាណអំពីដៃប្រជាជនត្រូវធ្វើកំណត់ហេតុទទួលវត្ថុបុរាណ ហើយបញ្ជូនកំណត់ហេតុមកអាជ្ញាធរខេត្ត ដើម្បីរាជរដ្ឋាភិបាលចាត់វិធានការផ្តល់ជូនវិញនូវការលើកទឹកចិត្ត សមស្របដល់សប្បុរសជនទាំងនោះឱ្យបានឆាប់រហ័សបំផុត ។

៦_ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ត្រូវសម្របសម្រួលបង្កើតក្រុមការងារដែលមានសមាសភាពមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងមហាផ្ទៃ ក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា និងស្ថាប័នពាក់ព័ន្ធ ដើម្បីពិភាក្សារិះរកមធ្យោបាយផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តនេះ ធ្វើយ៉ាងណាឱ្យបានឆាប់រហ័សបំផុត ។

៧_រាជរដ្ឋាភិបាលនឹងទុករយៈពេលប្រាំមួយខែ ជូនដល់ជនរួមជាតិទាំងអស់ ដែលកំពុងបន្តកាន់កាប់វត្ថុបុរាណ វត្ថុជាទីសក្ការៈនៃប្រជាជន ចាប់ពីថ្ងៃប្រកាសដំណឹងតទៅ ត្រូវធ្វើការបង្វែរជូនរាជរដ្ឋាភិបាលវិញឱ្យទាន់ពេលវេលា ។ ជនណាវិង្វេសដែលនៅតែបន្តតាស់បំផ្លាញប្រព្រឹត្តល្មើស និងមិនព្រមប្រគល់វត្ថុទាំងនោះមកថែរក្សាក្នុងសារមន្ទីរវិញទេ ជននោះនឹងត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពី កិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ។

ទទួលបានសារាចរណែនាំនេះគ្រប់ក្រសួង អាជ្ញាធរ ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ មីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ